ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 03 / 2012
ម៉ោង (Time/Heure) : 14 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៣៤

រៀបចំដោយ: សែ កុលវុឌ្ឍី និង **Roger PHILLIPS**

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Roger PHILLIPS, លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក ច័ន្ទ តារាវស្សី, លោក Tarik ABDULHAK, លោក Dale Lysak |
| ជនជាប់ចោទ៖ អៀង សារី , នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Andrew Ianuzzi |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anna Guisse |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT , លោក ហុង គឹមសួន, លោក Barnabé NEKUIE, លោក វ៉ែន ពៅ, លោក ឡោ ជុនធី, លោកស្រី ទីស្រ៊ីនណា, លោកស្រី ស៊ិន សូវន។ |
| ផ្សេងៗ៖ កញ្ញា Almaz TEFFERA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៥.៥៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | | ៤ ម៉ោង និង ២០ នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការអានកថាខណ្ឌដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ | អង្គជំនុំជម្រះ | ៩.១៥ | ១១.៥៤ |
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារឲ្យអៀង សារី<br>មេធាវីការពារឲ្យ នួន ជា | ១០.២៩<br>១១.៥៩ | ១០.៣០<br>១២.០១ |
| ការបញ្ជាក់អំពីស្ថានភាពនៃសំណើសុំបកប្រែឯកសារ | អង្គជំនុំជម្រះ,សហមេធាវីនាំមុខ | ១១.៥៦ | ១១.៥៩ |
| ការទទួលស្គាល់មេធាវីបរទេសការពារឲ្យជនជាប់ចោទ ខៀវ សំផន | អង្គជំនុំជម្រះ | ១៣.៣១ | ១៣.៣៥ |
| ការស្តាប់សេចក្តីសន្និដ្ឋានជំទាស់ទៅលើឯកសារដែលបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះដោយភាគី | អង្គជំនុំជម្រះ,មេធាវីការពារឲ្យនួន ជា, មេធាវីការពារឲ្យអៀង សារី | ១៣.៣៥ | ១៥.៥០ |
| ចម្លើយតបទៅនឹងសំណើរបស់ នួនជា | អង្គជំនុំជម្រះ | ១៥.៥០ | ១៥.៥៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការអានកថាខណ្ឌដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ**

ក្រឡាបញ្ជីជាតិបានអានកថាខណ្ឌដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយទាក់ទងនឹងសវនាការសំណុំរឿងលេខ០០២ វគ្គទី២ ដែលពាក់ព័ន្ធនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងប្រព័ន្ធទំនាក់ទំនងការងាររបស់កម្ពុជាប្រជាធិបតេយ្យ និងកថាខណ្ឌខ្លះស្តីពី "តួនាទី និងមុខងាររបស់ជនជាប់ចោទ" កថាខ ណ្ឌពាក់ព័ន្ធទាំងនេះមានដូចជា៖ កថាខណ្ឌ ៣៣-១១២, ៨៦៩-៨៧២, ៨៨០-៨៩២, ១០០១-១០១៥, ១១៣១-១១៤៤ និង១១៤៧-១១៥០។

**សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់។ អង្គជំនុំជម្រះ បានបដិសេធសំណើសុំនេះ ដោយហេតុថាសវនាការក្នុងថ្ងៃនេះគឺទាក់ទងនឹងបទចោទប្រកាន់ទៅលើជនជាប់ចោទ អៀង សារី ដែលតម្រូវឲ្យគាត់មានវត្តមាននៅក្នុងសវនាការនៅពេលព្រឹក។ សម្រាប់សវនាការនៅពេលរសៀល អង្គជំនុំជម្រះបានទទួលយកសំណើរបស់ជនជាប់ចោទ នួន ជា និងអៀង សារី ក្នុងការលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈឧបករណ៍សោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ មានភ្ជាប់ជាមួយនឹងកំណត់ហេតុនេះ) ។

**ការបញ្ជាក់អំពីស្ថានភាពនៃសំណើសុំបកប្រែឯកសារ**

អង្គជំនុំជម្រះបានសួរទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើការបញ្ជាក់អំពីស្ថានភាពនៃការស្នើសុំបកប្រែឯកសារជាក់លាក់មួយចំនួន។

**ការទទួលស្គាល់មេធាវីអន្តរជាតិការពារឲ្យជនជាប់ចោទ ខៀវ សំផន**

បន្ទាប់ពីបានធ្វើសម្បថនៅសាលាឧទ្ធរណ៍ អង្គជំនុំជម្រះបានទទួលស្គាល់លោកស្រីមេធាវី Anta GUISSE ជាមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន។

**ការស្តាប់សេចក្តីសន្និដ្ឋានជំទាស់ទៅលើការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះដោយភាគី**

អង្គជំនុំជម្រះបានស្តាប់ភាគីធ្វើការជំទាស់ទៅលើឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយភាគី (E109/1.1, E109/2.1, E109/4 និង E109/6.2)។ ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា អៀង សារី និងខៀវ សំផន បានធ្វើសេចក្តីសន្និដ្ឋានជំទាស់ទៅលើការដាក់ឯកសារផ្សេងៗដោយ

ភាគី។

**ចម្លើយតបទៅនឹងសំណើសុំរបស់ នួន ជា**

អង្គជំនុំជម្រះបានជូនដំណឹងទៅមេធាវីការពារឲ្យជនជាប់ចោទ នួន ជា ថាអង្គជំនុំជម្រះមិនអនុញ្ញាតិឲ្យមេធាវីការពារ ដាក់សេចក្តីសន្និដ្ឋានជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងសំណើសុំដាក់ឯកសារផ្សេងៗដោយភាគីនោះទេ ដោយហេតុថាមេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសន្និដ្ឋានជំទាស់ដោយផ្ទាល់មាត់នៅពេលរសៀលនេះ។ អង្គជំនុំជម្រះក៏បានជូនដំណឹងទៅមេធាវីការពារក្តីផងដែលថា អង្គជំនុំជម្រះនឹងមិនចេញសេចក្តីណែនាំណាមួយទាក់ទងនឹងការពិភាក្សាទៅលើការវាយតម្លៃនៃភស្តុតាងនោះទេ ដោយភាគីអាចទទួលបាននូវការវាយតម្លៃទៅលើភស្តុតាងនៅពេលបញ្ចប់នៃកិច្ចដំណើរការនីតិវិធី (យោងទៅវិធាន ៨៩)។

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា (១២.០១) និង អៀង សារី (១២.០១) ទៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ និងនាំជនជាប់ចោទ ខៀវ សំផន មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ១៣.៣០។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ១៣ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុលវុឌ្ឍី Roger PHILLIPS